គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា

Cooperation Committee
for Cambodia

Comité de Coopération
Pour le Cambodge

# ប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ច - ប្រទេសកម្ពុជា

## សេចក្តីណែនាំសម្រាប់អង្គការសង្គមស៊ីវិល










## ការយល់ដឹងអំពីបរិបទ

ល្បឿន និងវិសាលភាពនៃការអភិវឌ្ឍក្នុងប្រទេសកម្ពុជា ជានិច្ចកាលមិនសុទ្ធតែផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋនោះទេ ហើយកម្រនឹងមានការរួមបញ្ចូលណាស់។ ទោះជាយ៉ាងណា វិស័យឯកជនអាចចូលរួមចំណែកដ៏សំខាន់ចំពោះវិបុលភាពសេដ្ឋកិច្ចរបស់ប្រទេស ប្រសិនបើគោលការណ៍នៃប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ច អភិបាលកិច្ចល្អ តម្លាភាព គណនេយ្យភាព និងការគោរពសិទ្ធិមនុស្សត្រូវបានអនុវត្ត។ ខិត្តប័ណ្ណផ្សព្វផ្សាយនេះផ្តល់ជូននូវសេចក្តីណែនាំមួយចំនួនអំពីគោលការណ៍នៃប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ច និងយន្តការចំនួនពីរ ដែលអង្គការសង្គមស៊ីវិលអាចប្រើប្រាស់ដើម្បីលើកកម្ពស់ការចូលរួមអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

## តើប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ចគឺជាអ្វី?

ប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ច (RBC) មានន័យថាជាការអនុវត្តស្របតាមច្បាប់ និងបទប្បញ្ញត្តិជាតិ និងអន្តរជាតិ រួមទាំងសិទ្ធិមនុស្ស ការការពារបរិស្ថាន លក្ខខណ្ឌការងារ ពន្ធដារ ការសូកប៉ាន់ និងអំពើពុករលួយ សូម្បីតែនៅពេលដែលការអនុវត្តន៍ច្បាប់ទាំងនោះនៅទន់ខ្សោយក៏ដោយ។ វាគឺជា**កាតព្វកិច្ចចំពោះរដ្ឋភាគី**ក្នុងការតម្កល់ការទទួលខុសត្រូវទាំងនេះ។ សាជីវកម្មនានាត្រូវទទួលខុសត្រូវលើផលប៉ះពាល់សេដ្ឋកិច្ច សង្គម សិទ្ធិមនុស្ស និងបរិស្ថានដែលបង្កឡើងដោយសារសកម្មភាព និងទំនាក់ទំនងធុរកិច្ចរបស់ពួកគេទៅលើបុគ្គលិក កម្មករ សហគមន៍ និងសង្គម។ សាជីវកម្មនានាគួរអនុវត្តការពិនិត្យដ៏ត្រឹមត្រូវដើម្បី **<u>កំណត់ កាត់បន្ថយ បង្ការ</u>** និង**<u>ទទួលខុសត្រូវ</u>**<u>លើ</u>ផលប៉ះពាល់ត្រឡប់របស់ពួកគេ ទាំងផលប៉ះពាល់**ដែលកើតមានជាក់ស្តែង និងដែលអាចកើតមាន**។ RBC រាប់បញ្ចូលទាំងការទទួលខុសត្រូវរបស់ក្រុមហ៊ុន ដើម្បីដោះស្រាយការរំពឹងទុក និងក្តីបារម្ភនានារបស់សហគមន៍ និងសង្គម។ ធុរកិច្ចអាចមានការពាក់ព័ន្ធទៅលើបញ្ហារំលោភសិទ្ធិមនុស្សតាមរបៀបផ្សេងៗ តាមរយៈ**ការបង្កឲ្យកើតមាន ការចូលរួមចំណែក** ឬ**ការមានទំនាក់ទំនងដោយផ្ទាល់**ទៅនឹងការរំលោភបំពាននោះ។

## តើប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ច មានភាពខុសគ្នាពីទំនួលខុសត្រូវខាងសង្គមរបស់សាជីវកម្មយ៉ាងដូចម្តេច?

ទំនួលខុសត្រូវខាងសង្គមរបស់សាជីវកម្ម (CSR) គឺជារបៀបដែលក្រុមហ៊ុនមួយឆ្លើយតបទៅនឹងការរំពឹងទុករបស់សហគមន៍ពីសកម្មភាព និងទំនាក់ទំនងធុរកិច្ចរបស់ក្រុមហ៊ុននោះ។ ការរំពឹងទុកអាចត្រូវបានលើកឡើងដោយបុគ្គលិក កម្មករ សហជីព NGOs ឬតាមរយៈសារព័ត៌មាន។ CSR គឺជាការស្ម័គ្រចិត្ត។ នៅក្នុងប្រទេសជាច្រើន CSR លើសពីការធ្វើទានទៅទៀត តាមរយៈការផ្តល់គោលនយោបាយដោយក្រុមហ៊ុនស្តីពីរបៀបដែលធុរកិច្ចត្រូវបានគេរំពឹងទុកថានឹងចូលរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងលើកកម្ពស់ការទទួលខុសត្រូវរបស់ខ្លួនចំពោះសិទ្ធិមនុស្ស។ វាក៏អាចរួមបញ្ចូលនូវគម្រោងរបស់សហគមន៍ ដូចជាការ

សាងសង់សាលារៀន ឬគ្លីនិក ការផ្តល់អាហារថ្ងៃត្រង់សម្រាប់កម្មកររោងចក្រ ឬការទិញទំនិញពីអ្នកផ្គត់ផ្គង់ក្នុងមូលដ្ឋានជាដើម។ គម្រោងរបស់ CSR ដូចដែលបានលើកឡើងទាំងនេះ មិនជំនួសឲ្យការអនុវត្តស្របតាមច្បាប់ ឬផ្តល់លើសដល់ប្រតិបត្តិការរបស់ធុរកិច្ចដែលធ្វើឲ្យប៉ះពាល់ដល់សហគមន៍ បុគ្គលិក កម្មករ ឬបរិស្ថាននោះទេ។ ទំនួលខុសត្រូវរបស់សាជីវកម្មក្នុងគោរពសិទ្ធិមនុស្សមិនមែនជាការស្ម័គ្រចិត្តទេ។

## ការពិនិត្យដ៏ត្រឹមត្រូវលើប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ច

ការពិនិត្យដ៏ត្រឹមត្រូវរបស់ RBC គឺជាដំណើរការគ្រប់គ្រងមួយដើម្បីកំណត់ បង្ការ កាត់បន្ថយ និងទទួលខុសត្រូវលើ (រួមទាំងដំណោះស្រាយ) ផលប៉ះពាល់គ្រលប់ (ដ៏គ្រោះថ្នាក់) ដែលកើតមានជាក់ស្តែង និងដែលអាចកើតមាន។ ទាំងនេះរាប់បញ្ចូលទាំងផលប៉ះពាល់ដ៏គ្រោះថ្នាក់ដល់សហគមន៍ បុគ្គលិក កម្មករ ជនជាតិដើម និងបរិស្ថានផងដែរ។ ក្រុមហ៊ុនគួរកំណត់អទិភាពចំពោះសកម្មភាពរបស់ខ្លួន និងដោះស្រាយផលប៉ះពាល់ដ៏គ្រោះថ្នាក់បំផុតជាមុន។ ផលប៉ះពាល់គ្រលប់**ដែលកើតមានជាក់ស្តែង** បានកើតឡើងនៅក្នុងអតីតកាល ឬកំពុងកើតមាននាពេលបច្ចុប្បន្ន។ ផលប៉ះពាល់គ្រលប់**ដែលអាចកើតមាន** មានន័យថាមិនទាន់បានកើតមាននៅឡើយ ប៉ុន្តែទំនងជានឹងកើតមាននៅក្នុងពេលអនាគត ដោយសារតែសកម្មភាពរបស់ធុរកិច្ច។ ប្រទេសបារាំងបានអនុម័តច្បាប់ ដោយដាក់ចេញនូវការពិនិត្យដ៏ត្រឹមត្រូវទៅលើការរំលោភសិទ្ធិមនុស្សពីសំណាក់ក្រុមហ៊ុនអន្តរជាតិក្នុងសង្វាក់ផ្គត់ផ្គង់។ ក្រុមហ៊ុននានានឹងត្រូវតម្រូវឲ្យចេញផ្សាយផែនការពិនិត្យដ៏ត្រឹមត្រូវរបស់ពួកគេ ដែលនឹងមានប្រសិទ្ធភាពចាប់ពីខែមករា ឆ្នាំ២០១៨តទៅ។

## តើសង្គមស៊ីវិលអាចប្រើប្រាស់ប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ចដោយរបៀបណានៅក្នុងការងាររបស់ខ្លួន?

នៅពេលដែលសកម្មភាពនានារបស់ក្រុមហ៊ុនបង្កផលប៉ះពាល់អវិជ្ជមានមួយទៅលើសហគមន៍ ដីធ្លី និងជីវភាពរស់នៅរបស់ពួកគេ ជានិច្ចកាលវាមិនមានភាពងាយស្រួលនោះទេក្នុងការដឹងថាតើអ្នកណាគួរទទួលខុសត្រូវនោះ។ ចំណុចចាប់ផ្តើមមួយសម្រាប់សង្គមស៊ីវិលគឺការយល់ដឹងថាតើ RBC មានន័យយ៉ាងដូចម្តេច។ ទាំងនេះជួយធានាថាការចូលរួមពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុនអភិវឌ្ឍន៍គម្រោង និងការតស៊ូមតិ គឺជាយុទ្ធសាស្ត្រ ទិសដៅ ភាពពិតប្រាកដ និងមានភាពស្របគ្នាទៅនឹងកាតព្វកិច្ចច្បាប់ ទាំងច្បាប់របស់ក្រុមហ៊ុន និងច្បាប់របស់រដ្ឋភាគី។ RBC ផ្តល់ក្របខ័ណ្ឌមួយដើម្បីជួយដល់ CSOs ឲ្យឆ្លើយតបទៅនឹងផលប៉ះពាល់គ្រឡប់ដែលកើតមានជាក់ស្តែង និងដើម្បីព្យាយាម និងបង្ការមិនឲ្យមានផលប៉ះពាល់គ្រលប់ដែលអាចកើតមានឡើង។

## ប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ចនៅប្រទេសកម្ពុជា – សំណួរដែលត្រូវបានសួរញឹកញាប់ (FAQ)

សំណួរ និងចម្លើយសាមញ្ញទាំងនេះ អាចជួយលោកអ្នកឲ្យយល់ដឹងអំពីប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ច (RBC)។

**Q. តើទំនាក់ទំនងរវាងធុរកិច្ច និងសិទ្ធិមនុស្សគឺជាអ្វី?**

A. សិទ្ធិមនុស្សគឺជាស្តង់ដារអន្តរជាតិ សម្រាប់ឲ្យមនុស្សគ្រប់គ្នាទទួលបានការប្រព្រឹត្តិដោយស្មើភាព ដោយមានការគោរព និងសេចក្តីថ្លៃថ្នូ និងដោយគ្មានការរើសអើង។ ធុរកិច្ច ប្រៀបដូចទៅនឹងស្ថាប័នផ្សេងទៀតដែរមានការទទួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្សទាំងអស់ និងធ្វើឲ្យប្រាកដថា ពួកគេមិនបង្ក ឬចូលរួមចំណែកដល់ការបង្កឲ្យមានផលប៉ះពាល់ត្រលប់ដល់សិទ្ធិមនុស្សតាមរយៈសកម្មភាពផ្ទាល់របស់ខ្លួននោះទេ។ ធុរកិច្ចត្រូវតែដោះស្រាយផលប៉ះពាល់នានានៅពេលដែលផលប៉ះពាល់ទាំងនោះកើតមានឡើង។ ក្រុមហ៊ុនមួយត្រូវតែបង្ការ ឬកាត់បន្ថយផលប៉ះពាល់ដល់សិទ្ធិមនុស្ស ដែលមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងប្រតិបត្តិការ ផលិតផល ឬសេវាកម្មរបស់ខ្លួនតាមរយៈទំនាក់ទំនងធុរកិច្ចរបស់ក្រុមហ៊ុននោះ បើទោះជាធុរកិច្ចទាំងនោះមិនបានចូលរួមចំណែកបង្កឲ្យមានផលប៉ះពាល់ទាំងនោះក៏ដោយ។

**Q. តើ RBC អនុវត្តចំពោះក្រុមហ៊ុនក្នុងប្រទេសកម្ពុជាដែរឬទេ?**

A. RBC **និងការគោរពសិទ្ធិមនុស្សត្រូវអនុវត្តចំពោះក្រុមហ៊ុនទាំងអស់ ទាំងក្រុមហ៊ុនធំ និងតូច និងទាំងក្រុមហ៊ុនក្នុងស្រុក និងបរទេស។ ក្រុមហ៊ុនទាំងអស់ត្រូវតែអនុវត្តតាមច្បាប់ និងដោះស្រាយការរំពឹងទុក និងក្តីបារម្ភរបស់អ្នកទាំងឡាយណាដែលទទួលរងផលប៉ះពាល់ដោយសារប្រតិបត្តិការធុរកិច្ចរបស់ខ្លួន។**

**Q. តើវិស័យអ្វីដែលមានហានិភ័យខ្ពស់សម្រាប់ធុរកិច្ច និងសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា?**

A. គ្រប់វិស័យទាំងអស់មានសក្តានុពលបង្កឲ្យមានផលប៉ះពាល់អវិជ្ជមាន ប៉ុន្តែវិស័យមួយចំនួនបង្កផលប៉ះពាល់ច្រើនជាងវិស័យផ្សេងទៀត។ គម្រោងដែលពាក់ព័ន្ធនឹងធនធានធម្មជាតិ និងដីធ្លីមានហានិភ័យខ្ពស់។ វិស័យទាំងនេះរួមមាន រ៉ែ កសិកម្ម ព្រៃឈើ វារីអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវថ្នល់ និងផ្លូវដែកជាដើម។ វិស័យសំណង់ វាយណភ័ណ្ឌ និងបដិសណ្ឋារកិច្ច ក៏មានហានិភ័យខ្ពស់ផងដែរ។ វិស័យធនាគារក៏អាចស្ថិតក្នុងហានិភ័យផងដែរ ប្រសិនបើកម្ចី និងសេវាកម្មមានទំនាក់ទំនងផ្ទាល់ទៅនឹងគម្រោងដែលមិនគោរពសិទ្ធិមនុស្ស។

**Q. តើអ្នកណាជាជនរងគ្រោះដោយសារធុរកិច្ច និងការរំលោភសិទ្ធិមនុស្ស?**

A. បុគ្គលិក កម្មករ និងសមាជិកសហគមន៍ទាំងអស់ស្ថិតក្នុងហានិភ័យ។ ទោះជាយ៉ាងណា ហានិភ័យមានកាន់តែខ្ពស់សម្រាប់ប្រជាជនដែលរស់នៅក្នុងភាពក្រីក្រ ជនជាតិដើម ឬជនជាតិភាគតិច ស្ត្រីនិងកុមារី និងបុគ្គលិក កម្មករ។ អ្នករងគ្រោះអាចជាសហគមន៍នៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលដែលបាត់បង់ដីធ្លី ជីវភាពរស់នៅ និងប្រពៃណីរបស់ពួកគេ និងបុគ្គលិក កម្មករនៅឯរោងចក្រ និងការដ្ឋានសំណង់នៅតំបន់ទីក្រុង។

**Q. តើអ្នកណាដែលទទួលបានអត្ថប្រយោជន៍ពី RBC ?**

**A.** មនុស្សគ្រប់គ្នា។ សំខាន់ជាងនេះ សហគមន៍ និងបុគ្គលិកកម្មករ ដែលទទួលរងផលប៉ះពាល់ផ្ទាល់ពីសកម្មភាពធុរកិច្ច មានសិទ្ធិទទួលបានការគោរព។ រដ្ឋាភិបាលនានាដែលផ្តល់បរិយាកាសផ្នែកច្បាប់ប្រកបដោយអំណោយផលសម្រាប់ធុរកិច្ចប្រកបដោយការទទួលខុសត្រូវ ទំនងកាន់តែខ្លាំងថានឹងទាក់ទាញវិនិយោគិនដែលមានគុណភាពខ្ពស់ និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ក្រុមហ៊ុនដែលអនុវត្ត RBC ប្រហែលអាចទទួលបានអត្ថប្រយោជន៍ផ្នែកប្រកួតប្រជែង អាចការពារកេរ្តិ៍ឈ្មោះរបស់ខ្លួន និងជួយធានាឲ្យមានការអនុវត្តតាមច្បាប់ និងស្តង់ដារនានា ជាពិសេសក្នុងប្រទេសដែលមានអភិបាលកិច្ចខ្សោយ។ ក្រុមហ៊ុនដែលគោរពសិទ្ធិមនុស្សមិនសូវទំនងជាទទួលរងការអាក់ខានដល់ប្រតិបត្តិការរបស់ខ្លួនដែលបង្កឡើងដោយភាពចលាចលរបស់សហគមន៍ ឬជាទិសដៅយុទ្ធនាការរបស់ NGOs និងសហជីពនោះទេ។ ប្រជាពលរដ្ឋទាំងអស់ទទួលបានអត្ថប្រយោជន៍ នៅពេលដែលបរិស្ថានធម្មជាតិត្រូវបានការពារ ហើយប្រាក់ចំណូលរបស់ធុរកិច្ចត្រូវបានចំណាយលើសេវាកម្មសំខាន់ៗសម្រាប់មនុស្សទាំងអស់គ្នា ហើយមិនត្រូវបានបាត់បង់ទៅលើអំពើពុករលួយនោះទេ។

## ប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ចដែលអាចទទួលយកបាន

សហគមន៍ បុគ្គលិក កម្មករ និងជនជាតិដើមទទួលរងផលប៉ះពាល់នៅពេលដែលរដ្ឋភាគី និងក្រុមហ៊ុនមិនការពារ និងគោរពសិទ្ធិរបស់ពួកគេ។ ទាំងនេះរួមមាន សិទ្ធិទទួលបានលំនៅដ្ឋាន សិទ្ធិទទួលបានម្ហូបអាហារ សិទ្ធិទទួលបានសុខភាពល្អ សិទ្ធិទទួលបានការងារធ្វើ សិទ្ធិមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន សិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិចូលរួមក្នុងជីវិតវប្បធម៌។

ការយល់ដឹងអំពីថាតើអ្នកណាជាអ្នកទទួលខុសត្រូវ និងអ្នកណាគួរផ្តល់ដំណោះស្រាយមិនមែនជារឿងងាយស្រួលនោះទេ។ រចនាសម្ព័ន្ធធុរកិច្ច ភាពជាម្ចាស់កម្មសិទ្ធិធុរកិច្ច និងផែនការគម្រោងមានភាពស្មុគស្មាញ ហើយអាចមានការពាក់ព័ន្ធនឹងក្រុមហ៊ុនច្រើន។ ទាំងនេះអាចធ្វើឲ្យកិច្ចប្រឹងប្រែងតស៊ូមតិដើម្បីការពារ និងគោរពសិទ្ធិមនុស្សជួបការលំបាកសម្រាប់សហគមន៍ និងសង្គមស៊ីវិល។

## លទ្ធភាពទទួលបានព័ត៌មាន

**លទ្ធភាពទទួលបានព័ត៌មាន** មានសារៈសំខាន់ខ្លាំង។ សហគមន៍ បុគ្គលិក កម្មករ ជនជាតិដើម និងសង្គមស៊ីវិល ត្រូវការលទ្ធភាពទទួលបានព័ត៌មានអំពីគម្រោងដែលជះឥទ្ធិពលដល់ពួកគេ រួមទាំង៖

- ព័ត៌មានលម្អិតអំពីក្រុមហ៊ុនអភិវឌ្ឍន៍គម្រោង – តើពួកគេគឺជាអ្នកណា តើក្រុមហ៊ុនមានការិយាល័យកណ្តាលនៅទីណា តើដៃគូធុរកិច្ចរបស់ពួកគេជាអ្នកណា តើរដ្ឋាភិបាលដើរតួនាទីអ្វីនៅក្នុងគម្រោង?
- ហិរញ្ញប្បទានគម្រោង –តើអ្នកណាកំពុងផ្តល់មូលនិធិដល់គម្រោង?

- ការលើកទឹកចិត្ត និងការរៀបចំជូនពិសេស ដែលត្រូវបានផ្តល់ទៅឲ្យក្រុមហ៊ុន ឧ. គ្មានការបង់ពន្ធ ឬកាត់បន្ថយពន្ធជាដើម។
- វិសាលភាព និងទំហំនៃសកម្មភាពធុរកិច្ច–តើត្រូវការដីទំហំប៉ុន្មាន? តើគម្រោងមានរយៈពេលយូរប៉ុណ្ណា? តើគេនឹងសាងសង់អ្វី? តើអ្នកណានឹងទទួលបានការងារ ហើយនឹងមានការផ្លាស់ប្តូរទីលំនៅរបស់សហគមន៍ដែរឬទេ?
- ព័តមានលម្អិតអំពីកិច្ចសន្យា អាជ្ញាប័ណ្ណ ការអនុញ្ញាត និងកិច្ចព្រមព្រៀងដីសម្បទាន។
- ការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន –ធ្វើឡើងជាភាសាមួយដែលអាចយល់បាន។
- គោលនយោបាយដែលក្រុមហ៊ុនប្តេជ្ញាថានឹងអនុវត្ត រួមទាំងវិធានការការពារ និងលទ្ធភាពទទួលបានយន្តការប្តឹងតវ៉ា។

លទ្ធភាពទទួលបានព័ត៌មានជួយឲ្យយល់ដឹងអំពីប្រភេទផ្សេងៗនៃផលប៉ះពាល់ធុរកិច្ច ទាំងផលប៉ះពាល់ដែលកើតមានជាក់ស្តែង និងដែលអាចកើតមានឡើង។លទ្ធភាពទទួលបានព័ត៌មានជួយដល់ CSOs ដែលកំពុងធ្វើការងារសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

**ផលប៉ះពាល់ត្រឡប់ដែលកើតមានជាក់ស្តែង៖** ផលប៉ះពាល់ត្រឡប់ដែលកើតមានជាក់ស្តែងបានកើតមានឡើងក្នុងអតីតកាល ឬកំពុងកើតឡើងនាពេលបច្ចុប្បន្ន។

**ឧទាហរណ៍៖** ក្រុមហ៊ុនរ៉ែមួយបានបោះចោល ឬកំពុងបោះចោលកាកសំណល់ដែលមានសារធាតុពុលទៅក្នុងទន្លេ។ ទន្លេដែលទទួលរងសារធាតុពុលនេះបានប៉ះពាល់ដល់គុណភាពទឹក និងត្រី ដែលជះឥទ្ធិពលដល់សន្តិសុខស្បៀងអាហារ និងសុខភាពរបស់សហគមន៍នៅជុំវិញ និងអ្នកទាំងឡាយណាដែលរស់នៅខាងលើ ឬខាងក្រោមខ្សែទឹកនៃគម្រោងនេះ។

**ផលប៉ះពាល់ត្រឡប់ដែលអាចកើតមានឡើង៖** ផលប៉ះពាល់ត្រឡប់ដែលអាចកើតមានឡើង មិនទាន់កើតមានឡើងនៅឡើយទេ ប៉ុន្តែទំនងជានឹងកើតមានឡើងនៅពេលអនាគត ដោយសារសកម្មភាពរបស់ធុរកិច្ច។

**ឧទាហរណ៍៖** ធនាគារមួយផ្តល់កម្ចីទៅឲ្យក្រុមហ៊ុនស្ករសមួយដើម្បីអភិវឌ្ឍចម្ការ។ សហគមន៍នានានឹងបាត់បង់ដីធ្លីរបស់ពួកគេ ហើយនឹងត្រូវបានបង្ខំឲ្យពួកគេផ្លាស់ប្តូរទីលំនៅ។ នៅថ្ងៃអនាគត ជីវភាពរបស់ពួកគាត់នឹងត្រូវប៉ះពាល់ ហើយពួកគេនឹងធ្លាក់ទៅក្នុងស្ថានភាពកាន់តែលំបាកឡើង។

លទ្ធភាពទទួលបានព័ត៌មាន គួររៀបចំអោយមានការប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធ ហើយការចូលរួមរបស់សហគមន៍ក្នុងការធ្វើសេចក្តីសម្រេចចិត្ត រួមទាំងការយល់ព្រមពីជនជាតិដើមថាតើគម្រោងនេះគួរត្រូវដើរទៅមុខឬយ៉ាងណាផងដែរ។

យន្តការសំខាន់ៗចំនួនពីរត្រូវបានបង្កើតឡើង ដើម្បីលើកកម្ពស់ប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ច គឺ**គោលការណ៍**

**ណែនាំរបស់ស្ថាប័ន OECD សម្រាប់សហគ្រាសអន្តរជាតិ** និង**គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិសម្រាប់ធុរកិច្ច និងសិទ្ធិមនុស្ស។** គោលការណ៍ទាំងពីរនេះអនុវត្តក្នុងប្រទេសកម្ពុជា ហើយអាចត្រូវបានប្រើប្រាស់ដោយសង្គមស៊ីវិល។

## ហេតុអ្វីបានជាគោលការណ៍ណែនាំរបស់ស្ថាប័ន OECD សម្រាប់សហគ្រាសអន្តរជាតិមានសារៈសំខាន់?

គោលការណ៍ណែនាំរបស់ស្ថាប័ន OECD សម្រាប់សហគ្រាសអន្តរជាតិ (ហៅថាគោលការណ៍ណែនាំ) ជាអនុសាសន៍ដែលទទួលបានការគាំទ្រពីរដ្ឋាភិបាលសម្រាប់ក្រុមហ៊ុននានាពាក់ព័ន្ធនឹងប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ចនៅក្នុងប្រតិបត្តិការនៅទូទាំងពិភពលោករបស់ខ្លួន។

**សេចក្តីសង្ខេបនៃគោលការណ៍ណែនាំរបស់ស្ថាប័ន OECD សម្រាប់សហគ្រាសអន្តរជាតិ**

- គោលការណ៍ណែនាំនេះរួមបញ្ចូលទាំងគោលការណ៍ និងស្តង់ដារនានាដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ការងារ បរិស្ថាន ការបង្ហាញព័ត៌មាន ការសូកប៉ាន់ អំពើពុករលួយ និងពន្ធដារ។
- គោលការណ៍ណែនាំនេះផ្តល់ការរំពឹងទុកសម្រាប់ក្រុមហ៊ុននានា ដើម្បីអនុវត្តការពិនិត្យដ៏ត្រឹមត្រូវ និងការប្រឹក្សារបស់ភាគីពាក់ព័ន្ធ។
- គោលការណ៍ណែនាំនេះអនុវត្តចំពោះប្រទេសទាំងអស់ដែលចូលជាសមាជិក OECD ។ គោលការណ៍ណែនាំនេះអនុវត្តចំពោះប្រតិបត្តិការរបស់សហគ្រាសដែលកំពុងប្រតិបត្តិការក្នុង និងពីប្រទេសដែលជាសមាជិកគោលការណ៍ណែនាំ។
- វាជាគោលការណ៍ស្ម័គ្រចិត្តសម្រាប់ក្រុមហ៊ុននានា ប៉ុន្តែចងភ្ជាប់ជាកាតព្វកិច្ចសម្រាប់រដ្ឋាភិបាលដែលបានចុះហត្ថលេខាលើគោលការណ៍ណែនាំនេះ មានន័យថារដ្ឋាភិបាលទាំងនោះត្រូវតែលើកកម្ពស់គោលការណ៍ណែនាំ ចំពោះក្រុមហ៊ុននានា និងស៊ើបអង្កេតករណីផលប៉ះពាល់ត្រឡប់ដែលបង្កឡើងដោយក្រុមហ៊ុន (ដូចជាការមិនគោរពសិទ្ធិមនុស្ស និងការខូចខាតដល់បរិស្ថាន) និងបង្កើត National Contact Points (NCP)។
- គោលការណ៍ណែនាំនេះត្រូវបានលើកកម្ពស់ និងអនុវត្តដោយរដ្ឋាភិបាលនានាតាមរយៈ National Contact Points (NCP) ដែលជាជនបង្គោល។
- គោលការណ៍ណែនាំនេះមានយន្តការប្តឹងតវ៉ាមួយ។ វាអាចត្រូវបានប្រើប្រាស់ដើម្បីចាប់បង្ខំឲ្យក្រុមហ៊ុនទទួលខុសត្រូវតាមរយៈរដ្ឋភាគីរបស់ប្រទេសដែលជាសមាជិករបស់គោលការណ៍ណែនាំនេះ។ NCP ទទួលខុសត្រូវលើការស៊ើបអង្កេតបណ្តឹងនានា។
- គោលការណ៍ណែនាំមានការគាំទ្រពីធុរកិច្ច សហជីព រដ្ឋាភិបាល និង NGOs មួយចំនួន។

National Contact Points ត្រូវតែលើកកម្ពស់គោលការណ៍ណែនាំ ហើយក៏មានមុខងារជាយន្តការប្តឹងតវ៉ាមួយផងដែរ។ National Contact Points អាចត្រូវបានប្រើប្រាស់ដើម្បីចាប់បង្ខំឲ្យក្រុមហ៊ុនទទួលខុសត្រូវតាមរយៈរដ្ឋភាគី។ NCP ទទួលខុសត្រូវលើការដោះស្រាយជម្លោះ ជាពិសេសតាមរយៈការសម្រុះសម្រួល និងការផ្សះផ្សារ។ ទោះជាយ៉ាងណា មិនមែន NCP ទាំងអស់ធ្វើការងារសុទ្ធតែមានប្រសិទ្ធភាពនោះទេ។

**សូមស្វែងយល់បន្ថែមតាមរយៈគេហទំព័រ៖** http://www.oecd.org/corporate/mne/oecdguidelinesformultinationalenterprises.htm

## សំណួរដែលត្រូវបានសួរញឹកញាប់ (FAQ)

### 1. តើគោលការណ៍ណែនាំនេះអនុវត្តក្នុងប្រទេសកម្ពុជាដែរឬទេ?

ប្រទេសកម្ពុជាមិនមែនជាសមាជិករបស់ស្ថាប័ន OECD នោះទេ ប៉ុន្តែក្រុមហ៊ុនជាច្រើនដែលកំពុងធ្វើធុរកិច្ចក្នុងប្រទេសកម្ពុជាមកពីប្រទេសមួយចំនួនក្នុងចំណោមប្រទេសចំនួន ៤៦ ដែលបានអនុម័តគោលការណ៍ណែនាំ OECD នេះ។ គោលការណ៍ណែនាំនេះពិតជាអនុវត្តចំពោះធុរកិច្ចដែលមកពីប្រទេសជាសមាជិករបស់ស្ថាប័ន OECD ដែលរួមមាន ប្រទេសអូទ្រីស កាណាដា បារាំង សហរដ្ឋអាមេរិក អាល្លឺម៉ង់ កូរ៉េ និងជប៉ុន។ល។ នៅពេលក្រុមហ៊ុនទាំងនោះធ្វើធុរកិច្ចក្នុងប្រទេសកម្ពុជា។

### 2. តើគោលការណ៍ណែនាំនេះអនុវត្តចំពោះក្រុមហ៊ុនមកពីអាស៊ីដែរឬទេ?

មានតែប្រទេសជប៉ុន និងកូរ៉េប៉ុណ្ណោះដែលបានអនុវត្តគោលការណ៍ណែនាំនេះ ដូច្នេះគោលការណ៍ណែនាំនេះពិតជាអនុវត្តចំពោះក្រុមហ៊ុននានាមកពីប្រទេសកូរ៉េ និងជប៉ុន ដែលធ្វើធុរកិច្ចនៅកម្ពុជា។ យន្តការប្តឹងតវ៉ា អាចត្រូវបានប្រើប្រាស់ប្រសិនបើក្រុមហ៊ុនមកពីប្រទេសទាំងនោះបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានទៅលើបុគ្គលិក កម្មករ សហគមន៍ និងបរិស្ថានក្នុងប្រទេសកម្ពុជា។

គោលការណ៍ណែនាំនេះ មិនអនុវត្តចំពោះក្រុមហ៊ុនមកពីប្រទេសចិន ឥណ្ឌា ថៃ វៀតណាម ម៉ាឡេស៊ី។ល។ ឡើយ។ យន្តការប្តឹងតវ៉ាមិនអាចត្រូវបានប្រើប្រាស់នោះទេ ប្រសិនបើក្រុមហ៊ុនមួយមកពីប្រទេសទាំងនេះបង្កផលប៉ះពាល់នៅកម្ពុជានោះ។ ទោះជាយ៉ាងណា ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនមួយមកពីប្រទេសថៃ ឬចិនបានទទួលកម្ចី ឬសេវាកម្មផ្សេងទៀតពីធនាគារ ឬក្រុមហ៊ុនមួយដែលមានការិយាល័យកណ្តាលនៅក្នុងប្រទេសជាសមាជិករបស់ស្ថាប័ន OECD មួយដូចជាប្រទេសន័រវែស ឬហ្វាំងឡង់នោះ យន្តការប្តឹងតវ៉ានេះអាចត្រូវបានប្រើប្រាស់ដើម្បីនាំយកករណីមួយប្រឆាំងនឹងធនាគារ ឬក្រុមហ៊ុននោះពីបទបង្ក ចូលរួមចំណែក ឬមានទំនាក់ទំនងផ្ទាល់ទៅនឹងផលប៉ះពាល់អវិជ្ជមានក្នុងប្រទេសកម្ពុជា។

## 3. តើយន្តការប្តឹងតវ៉ាដំណើរការយ៉ាងដូចម្តេច?




"ភាគីចាប់អារម្មណ៍" មួយចំនួនអាចធ្វើការប្តឹងតវ៉ាបានរួមទាំង បុគ្គល បុគ្គលិក NGO សហជីព កម្មករ និងសហគមន៍ ដែលទទួលរងផលប៉ះពាល់អវិជ្ជមានពីសកម្មភាពធុរកិច្ច។ ការប្តឹងតវ៉ាអាចត្រូវបានធ្វើឡើងប្រឆាំងនឹងក្រុមហ៊ុនដែលប្រតិបត្តិការក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ប្រសិនបើក្រុមហ៊ុននោះមានប្រភពមកពីប្រទេសដែលជាសមាជិក OECD ហើយត្រូវតែផ្តល់ព័ត៌មានលម្អិតថាតើបទប្បញ្ញត្តិជាក់លាក់ណាមួយនៃគោលការណ៍ណែនាំ OECD ត្រូវបានរំលោភ។ វាត្រូវបានរាប់បញ្ចូលទាំងផលប៉ះពាល់ត្រឡប់នៅក្នុងសង្វាក់ផ្គត់ផ្គង់របស់ក្រុមហ៊ុនផងដែរ (ឧ. សម្ភារៈម៉ាកយីហោល្បីរបស់ពិភពលោកមួយទទួលបានការផ្គត់ផ្គង់ពីរោងចក្រមួយក្នុងប្រទេសកម្ពុជា) និងទំនាក់ទំនងធុរកិច្ច (រាល់ប្រភេទដៃគូធុរកិច្ចទាំងអស់ ឧ. ធនាគារមួយដែលមានការិយាល័យកណ្តាលនៅក្នុងប្រទេសជាសមាជិករបស់ OECD គាំទ្រដល់ធុរកិច្ចកសិពាណិជ្ជកម្មដែលបង្កឲ្យមានការរំលោភយកដីធ្លី)។

"ការត្រួតពិនិត្យករណី (Case Check)" របស់បណ្តាញ OECD Watch អាចជួយលោកអ្នកឲ្យរៀបចំការប្តឹងតវ៉ារបស់លោកអ្នកបាន។

**សូមស្វែងយល់បន្ថែមតាមរយៈគេហទំព័រ៖** http://www.oecdwatch.org/oecd-watch-case-check

ការប្តឹងតវ៉ា ដែលហៅថា "ការកើតឡើងជាក់លាក់" ត្រូវបានដាក់ជូនទៅកាន់ NCP។ ប្រទេសកម្ពុជាមិនមាន NCP ឡើយហេតុដូច្នេះការប្តឹងតវ៉ានឹងត្រូវប្តឹងទៅកាន់ NCP របស់ប្រទេសដែលជាមូលដ្ឋានរបស់ក្រុមហ៊ុននោះ។ ឧទាហរណ៍ ការប្តឹងតវ៉ាមួយអំពីក្រុមហ៊ុនអូស្ត្រាលីដែលកំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជា នឹងត្រូវដាក់ទៅកាន់ NCP នៅអូស្ត្រាលី។

ប្រសិនបើការប្តឹងតវ៉ាមួយត្រូវបានទទួលដោយ NCP ជាធម្មតានឹងមានការចំណាយពេលយ៉ាងហោចណាស់ ១២ ខែទើបអាចឈានដល់ការសម្របសម្រួល និងបញ្ចប់បាន ហើយជួនកាលអាចចំណាយពេលយូរជាងនេះ។ មិនមែនគ្រប់បណ្តឹងទាំងអស់ត្រូវបានទទួលយកនោះទេ។ បណ្តឹងជាច្រើនត្រូវបានច្រានចោល ឬ NCP មិនឆ្លើយតប។ NCP មួយចំនួនអនុវត្តការទទួលខុសត្រូវរបស់ខ្លួនបានប្រសើរជាង NCP ផ្សេងទៀត។ NCP ខ្លះនឹងបង្ហាញភាពច្បាស់លាស់ (និងជាសាធារណៈ) ថាក្រុមហ៊ុនបានរំលោភគោលការណ៍ណែនាំ ហើយ NCP ផ្សេងទៀតមិនធ្វើដូច្នេះទេ។ ជនរងគ្រោះភាគច្រើនដែលបណ្តាលមកពីប្រតិបត្តិការមិនត្រឹមត្រូវរបស់សាជីវកម្ម ទទួលបានដំណោះស្រាយយ៉ាងកម្រ។

**សូមស្វែងយល់បន្ថែមតាមរយៈគេហទំព័រ៖** http://www.oecdwatch.org/

## គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស

គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស (UNGP) បង្កើតឡើងសម្រាប់រដ្ឋភាគី និងក្រុមហ៊ុន។ គោលការណ៍ណែនាំនេះមានចែងអំពីភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋភាគីនិងក្រុមហ៊ុន ដើម្បីការពារ និងគោរពសិទ្ធិមនុស្សក្នុងសកម្មភាពធុរកិច្ច។ គោលការណ៍ណែនាំនេះលើកកម្ពស់លទ្ធភាពទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពសម្រាប់បុគ្គល និងក្រុមដែលទទួលរងផលប៉ះពាល់ត្រឡប់។ គោលការណ៍ណែនាំនេះអាចត្រូវបានប្រើប្រាស់ដោយសង្គមស៊ីវិលសម្រាប់ការពិនិត្យតាមដានការពិនិត្យដ៏ត្រឹមត្រូវ ដែលជាចំណុចគោលសម្រាប់ការអនុវត្តដ៏ប្រសើរមួយ និងដើម្បីពង្រឹងច្បាប់ជាតិ។

សេចក្តីសង្ខេបនៃគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស (UNGP)

- UNGP រួមបញ្ចូល "ក្របខ័ណ្ឌការពារ គោរព និងដោះស្រាយ"។ វាគឺជាភារកិច្ចរបស់រដ្ឋភាគី ដើម្បីការពារសិទ្ធិមនុស្ស ការទទួលខុសត្រូវរបស់សាជីវកម្ម ដើម្បីគោរពសិទ្ធិមនុស្ស និងដើម្បីធានាឲ្យមានលទ្ធភាពទទួលបានដំណោះស្រាយសម្រាប់ជនរងគ្រោះពីធុរកិច្ចដែលពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្ស។
- UNGP បង្ហាញនូវជំហាននានាសម្រាប់រដ្ឋភាគី ដើម្បីជំរុញឲ្យធុរកិច្ចគោរពសិទ្ធិមនុស្ស និងផ្តល់ការណែនាំសម្រាប់រដ្ឋាភិបាលតាមរយៈគោលនយោបាយ ច្បាប់ បទប្បញ្ញត្តិ និងការវិនិច្ឆ័យ ដើម្បីបង្ការ កាត់បន្ថយ និងដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្ស។
- UNGP ផ្តល់ផែនទីបង្ហាញផ្លូវ និងការទទួលខុសត្រូវមួយសម្រាប់ធុរកិច្ច ដើម្បីគោរពសិទ្ធិមនុស្ស និងកំណត់ បង្ការ កាត់បន្ថយ និងទទួលខុសត្រូវលើផលប៉ះពាល់ត្រឡប់**ដែលកើតមានជាក់ស្តែង** និង**ដែលអាចកើតមាន** និងការរំលោភសិទ្ធិមនុស្សដោយសារសកម្មភាពរបស់ខ្លួន។ ស្ថិតក្រោម UNGP រាល់ក្រុមហ៊ុនទាំងអស់មានការទទួលខុសត្រូវលើការការពារសិទ្ធិមនុស្សនៅទីណាដែលក្រុមហ៊ុនទាំងនោះប្រតិបត្តិការ ដោយមិនគិតពីទំហំប្រតិបត្តិការរបស់ខ្លួន និងថាតើរដ្ឋភាគីបំពេញកាតព្វកិច្ចផ្ទាល់របស់ខ្លួនដែរឬយ៉ាងណា។
- UNGP គឺជាគោលការណ៍ណែនាំគោលមួយសម្រាប់ភាគីពាក់ព័ន្ធ រួមទាំងម្ចាស់ជំនួយ ដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (ឧ. សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ "IFC" របស់ធនាគារពិភពលោក) ដើម្បីពិនិត្យតាមដានការគោរពសិទ្ធិមនុស្សរបស់ធុរកិច្ច ដើម្បីលើកទឹកចិត្តឲ្យមានការពិនិត្យដ៏ត្រឹមត្រូវពីសំណាក់ដៃគូសាធារណៈ និងឯកជន និងដើម្បីមិនឲ្យមានការរារាំងដល់លទ្ធភាពរបស់អ្នកទទួលផលក្នុងការឆ្លើយតបទៅនឹងការទទួលខុសត្រូវរបស់ខ្លួនក្នុងការគោរពសិទ្ធិមនុស្ស។
- UNGP គឺជាស្តង់ដារសកលលោកដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងក្របខ័ណ្ឌអន្តរជាតិផ្សេងៗ រួមទាំងគោលការណ៍ណែនាំ OECD សម្រាប់សហគ្រាសអន្តរជាតិផងដែរ។

**សូមស្វែងយល់បន្ថែមតាមរយៈគេហទំព័រ៖**
http://www.ohchr.org/Documents/Publications/GuidingPrinciplesBusinessHR_EN.pdf
**សូមចូលទៅកាន់គេហទំព័រនេះ៖**https://www.youtube.com/watch?v=BCoL6JVZHrA&authuser=0

**សូមស្វែងយល់បន្ថែមតាមរយៈគេហទំព័រ៖**
http://cambodia.ohchr.org/~cambodiaohchr/sites/default/files/Guiding%20Principles%20on%20Business%20and%20Human%20Rights%20Implementing%20the%20United%20Nations%20-Protect%20Respect%20and%20Remedy-%20Framework%20Khmer.pdf
**សូមចូលទៅកាន់គេហទំព័រនេះ៖** https://www.youtube.com/watch?v=UHTEvt15I04.

## សំណួរដែលត្រូវបានសួរញឹកញាប់ (FAQ)

### ១. តើ UNGP អនុវត្តនៅក្នុងប្រទេសកម្ពុជាដែរឬទេ?

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នភាគច្រើននៃសន្ធិសញ្ញាសិទ្ធិមនុស្សស្នូលចំនួនប្រាំបួន។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមានចែងអំពីកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ៖ "*ព្រះរាជាណាចក្រកម្ពុជាត្រូវទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កត្តិកាសញ្ញានិងអនុសញ្ញាទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ*"។ UNGP ទទួលស្គាល់កាតព្វកិច្ចដែលមានស្រាប់របស់រដ្ឋភាគីក្នុងការគោរព ការពារ និងការបំពេញតាមសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន មានន័យថាស្តង់ដារស្តីពីធុរកិច្ច និងសិទ្ធិមនុស្សអាចអនុវត្តបានដោយផ្ទាល់ចំពោះព្រះរាជាណាចក្រកម្ពុជាតាមរយៈការប្តេជ្ញាចិត្តតាមច្បាប់អន្តរជាតិ និងច្បាប់ក្នុងស្រុករបស់ខ្លួន។ ស្តង់ដារទាំងនេះអនុវត្តចំពោះក្រុមហ៊ុនក្នុងស្រុក និងបរទេស ទាំងតូច ទាំងធំដែលកំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជា។

### ២. តើ UNGP ចងភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ដែរឬទេ?

UNGP បញ្ជាក់យ៉ាងច្បាស់ និងលម្អិតអំពីបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹង**ស្តង់ដារអន្តរជាតិ និងសិទ្ធិមនុស្សដែលមានស្រាប់**ដែលបទប្បញ្ញត្តិមួយចំនួនចងភ្ជាប់កាតព្វកិច្ចស្របច្បាប់ចំពោះរដ្ឋភាគី រួមទាំងប្រទេសកម្ពុជាផងដែរ។ គោលការណ៍ទាំងនេះផ្តល់ការណែនាំអំពីរបៀបដាក់ដំណើរការបទប្បញ្ញត្តិទាំងនោះ។ UNGP មិនត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋភាគី ហើយមិនបង្កើតច្បាប់អន្តរជាតិថ្មីនោះទេ។ រាល់រដ្ឋភាគីទាំងអស់មានភារកិច្ចការពារមនុស្សគ្រប់គ្នាដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួនពីការរំលោភសិទ្ធិមនុស្ស ដែលត្រូវបានបង្កឡើងដោយក្រុមហ៊ុននានា។ ក្នុងករណីជាច្រើន វាគឺជាកាតព្វកិច្ចផ្លូវច្បាប់មួយ តាមរយៈការប្តេជ្ញាចិត្ត

របស់ខ្លួនចំពោះសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលចងភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់។ មានការរំពឹងទុកជាសកលថា រដ្ឋភាគី និងក្រុមហ៊ុននឹងអនុលោមតាម UNGP ។

### ៣. តើ UNGP មានយន្តការប្តឹងតវ៉ាដែរឬទេ?

នៅក្នុងប្រទេសកម្ពុជា ក៏ដូចនៅទីកន្លែងផ្សេងទៀតដែរ រដ្ឋភាគីមានភារកិច្ចមួយក្នុងការការពារសិទ្ធិមនុស្ស រួមទាំងលទ្ធភាពទទួលបានដំណោះស្រាយសម្រាប់អ្នកទាំងឡាយណា ដែលទទួលរងផលប៉ះពាល់ត្រឡប់ដោយសារសកម្មភាពធុរកិច្ចផងដែរ។ UNGP អះអាងថាភារកិច្ចរបស់រដ្ឋភាគីក្នុងការការពារសិទ្ធិមនុស្សរួមបញ្ចូលទាំងការធានាថា ប្រសិនបើក្រុមហ៊ុនមានការរំលោភសិទ្ធិមនុស្ស រដ្ឋភាគីនានា នឹងផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពដល់អ្នកទាំងឡាយណា ដែលទទួលរងផលប៉ះពាល់ តាមរយៈមធ្យោបាយតុលាការ រដ្ឋបាល ច្បាប់ ឬមធ្យោបាយសមស្របផ្សេងទៀត នៅពេលណាការរំលោភបែបនេះកើតមានឡើង។
UNGP មិនមានយន្តការប្តឹងតវ៉ាផ្ទាល់ខ្លួននោះទេ ប៉ុន្តែគោលការណ៍ណែនាំទាំងនេះបានចែងយ៉ាងច្បាស់ថា លទ្ធភាពទទួលបានដំណោះស្រាយ មិនមែនអនុវត្តចំពោះតែរដ្ឋភាគីនោះទេ។ ក្រុមហ៊ុនគួរសហការជាមួយយន្តការតុលាការ និងផ្តល់ ឬសហប្រតិបត្តិការជាមួយ យន្តការកម្រិតប្រតិបត្តិការសម្រាប់ដោះស្រាយការប្តឹងតវ៉ាពីបុគ្គល និងសហគមន៍ដែលអាចទទួលរងផលប៉ះពាល់ត្រលប់ដោយសារសកម្មភាពធុរកិច្ចរបស់ខ្លួន។
UNGP បង្កើតបញ្ជីមួយស្តីពី**លក្ខណៈវិនិច្ឆ័យយន្តការប្តឹងតវ៉ាមិនមែនតុលាការ**ប្រកបដោយប្រសិទ្ធភាព។ យន្តការប្តឹងតវ៉ាមិនមែនតុលាការ គួរតែមានភាពស្របច្បាប់ អាចទទួលយកបាន អាចទស្សទាយបាន មានសមធម៌ មានតម្លាភាព ស្របតាមសិទ្ធិ ជាប្រភពរៀនសូត្រមិនចេះរីងស្ងួត ការពារពីអំពើពុករលួយ និងមិនរងឥទ្ធិពលនយោបាយ។ ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពសម្រាប់ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្សដោយក្រុមហ៊ុន មិនមែនគ្រាន់តែជាការអនុវត្តទំនាក់ទំនងសាធារណៈមួយនោះទេ។

### ៤. តើ UNGP អាចត្រូវបានប្រើប្រាស់ដោយសង្គមស៊ីវិលយ៉ាងដូចម្តេច?

UNGP ផ្តល់ក្របខ័ណ្ឌមួយសម្រាប់សង្គមស៊ីវិល (CSO) និងជនរងគ្រោះដើម្បីវាស់វែងថា តើរដ្ឋភាគីនិងក្រុមហ៊ុនបានចាត់វិធានការដើម្បីការពារ និងគោរពសិទ្ធិមនុស្ស និងផ្តល់លទ្ធភាពទទួលបានដំណោះស្រាយដែរឬយ៉ាងណា។ ឧទាហរណ៍៖ CSO បានប្រើប្រាស់ក្របខ័ណ្ឌ UNGP ដើម្បីវិភាគហានិភ័យនៅក្នុងវិស័យជាក់លាក់នានាដូចជាវិស័យនិស្សារណកម្ម ហើយក្រោយមកតស៊ូមតិ ដើម្បីឲ្យមានការកែលម្អ។ UNGP ត្រូវបានប្រើប្រាស់ដើម្បីជួយបង្កើត និងកែលម្អយន្តការប្តឹងតវ៉ា។ UNGP ត្រូវបានប្រើប្រាស់



ដើម្បីជាការណែនាំសម្រាប់ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្សពីសំណាក់សាជីវកម្ម និងសម្រាប់គោលបំណងតស៊ូមតិរបស់ CSOs។ គោលការណ៍ UNGP ទាំងនេះអាចត្រូវបានប្រើប្រាស់ដោយ CSO និងភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់ ដើម្បីគាំទ្រដល់ការដាក់បណ្តឹងទៅកាន់ស្ថាប័ន Universal Periodic Review របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។

## ប្រភពព័ត៌មាន និងការគាំទ្រ

ប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ច (RBC) អាចជាវិស័យការងារថ្មីមួយសម្រាប់ស្ថាប័នរបស់អ្នក។ ការធ្វើការងារជាមួយស្ថាប័នផ្សេងទៀត និងការចែករំលែកបទពិសោធន៍ ជំនាញ និងធនធាន នឹងនាំមកនូវលទ្ធផលល្អប្រសើរ។

## ក្នុងប្រទេសកម្ពុជា

បញ្ជីខាងក្រោម រួមមានអង្គការមួយចំនួនដែលធ្វើការងារលើ RBC ក្នុងប្រទេសកម្ពុជា។ អ្នកក៏អាចទាក់ទងសហជីព យុវជន ជនជាតិដើម និងក្រុមជំនួយផ្នែកច្បាប់ផងដែរ។ សូមចូលមើលគេហទំព័រទាំងនេះដើម្បីទទួលបានការណែនាំ ឧបករណ៍ និងធនធាននានា។

- អង្គការ ActionAid
- អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា - CCC
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា - CCHR
- CSR Cambodia Platform
- អង្គការ Dan Church Aid - DCA
- អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព - DPA
- អង្គការសមធម៌កម្ពុជា
- សមាគមខ្មែរលើ
- អង្គការ Inclusive Development International - IDI
- លីកាដូ -សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស
- អង្គការមាតាធម្មជាតិ
- អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
- អង្គការOxfam

- អង្គការតម្លាភាពអន្តរជាតិ TI
- ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា (UNOHCHR)

UNOHCHR Cambodia បានបោះពុម្ពផ្សាយឯកសារស្តីអំពីធុរកិច្ច និងសិទ្ធិមនុស្សជាភាសាខ្មែរ និងអង់គ្លេស រួមទាំង សំណួរដែលត្រូវបានសួរញឹកញាប់ស្តីពីUNGP។

## ជាសកល

ជាលក្ខណ:អន្តរជាតិ មានការងារជាច្រើនទាក់ទងនឹង RBC ដែលត្រូវធ្វើ។ ខាងក្រោមនេះគឺជាចំណុចចាប់ផ្តើមមួយ។

បណ្តាញ OECD Watch គឺជាបណ្តាញអន្តរជាតិមួយរបស់អង្គការសង្គមស៊ីវិល ដែលលើកកម្ពស់ការទទួលខុសត្រូវរបស់សាជីវកម្ម។ គេហទំព័ររបស់បណ្តាញនេះមានព័ត៌មានអំពីគោលការណ៍ណែនាំ OECD សម្រាប់សហគ្រាសអន្តរជាតិ រួមទាំង មូលដ្ឋានទិន្នន័យសំណុំរឿងមួយ ការណែនាំសម្រាប់ CSOs អំពីរបៀបប្រើប្រាស់យន្តការប្តឹងតវ៉ាគោលការណ៍ណែនាំ និងការត្រួតពិនិត្យករណី ដើម្បីជួយអ្នកឲ្យរៀបចំពាក្យបណ្តឹងរបស់អ្នក។

មជ្ឈមណ្ឌលស្រាវជ្រាវសាជីវកម្មអន្តរជាតិ (SOMO) មានព័ត៌មានល្អៗអំពីវិស័យផ្សេងៗ ដូចជា វិស័យនិស្សារណកម្ម កសិកម្ម វាយណភ័ណ្ឌ ដីធ្លី និងផ្សេងៗទៀត។ មជ្ឈមណ្ឌលនេះក៏មានឧបករណ៍ និងការណែនាំស្តីពីយន្តការប្តឹងតវ៉ា និងរបៀបដាក់ពាក្យបណ្តឹងផងដែរ។ **សូមមើល**វីដេអូខ្លីនេះ។

មជ្ឈមណ្ឌលធនធានធុរកិច្ច និងសិទ្ធិមនុស្សមានព័ត៌មានជាច្រើន។ សូមចុះឈ្មោះដើម្បីទទួលបានព័ត៌មានបច្ចុប្បន្នភាពប្រចាំសប្តាហ៍។ មជ្ឈមណ្ឌល នេះមានបញ្ជីមួយដែលមានរាយឈ្មោះរបស់ស្ថាប័នធុរកិច្ច និងសិទ្ធិមនុស្សឈានមុខគេ។

## អំពីខិត្តប័ណ្ណផ្សព្វផ្សាយ

ខិត្តប័ណ្ណផ្សព្វផ្សាយនេះផ្តល់សេចក្តីណែនាំមួយចំនួនអំពីប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ច និង ធុរកិច្ចនិងសិទ្ធិមនុស្ស។ ខិត្តប័ណ្ណផ្សព្វផ្សាយនេះក៏ផ្តល់ផងដែរនូវទិដ្ឋភាពទូទៅនៃគោលការណ៍ណែនាំរបស់ស្ថាប័ន OECD សម្រាប់សហគ្រាសអន្តរជាតិ និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស។ យន្តការណ៍ឈានមុខគេទាំងពីរនេះអាចជួយលើកកម្ពស់ប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ច ហើយអាចត្រូវបានប្រើប្រាស់ដើម្បីចាប់បង្ខំឲ្យសាជីវកម្មនានាទទួលខុសត្រូវលើសកម្មភាពរបស់ពួកគេ។ វាមិនងាយស្រួលក្នុងការសម្រេចបាននោះទេ។ CCC ផ្តល់អនុសាសន៍ដល់សហគមន៍ សង្គមស៊ីវិល និងបុគ្គលិក កម្មករដែលរងផលប៉ះពាល់ ត្រូវព្យាយាមចូលរួមដោយផ្ទាល់ជាមួយក្រុមហ៊ុន ដើម្បីដោះស្រាយបណ្តឹងតវ៉ា និងដោះស្រាយផលប៉ះពាល់ត្រឡប់ជាមុនសិន។

## អំពី គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩០។ CCC គឺជាអង្គការសមាជិកភាពអង្គការមិនមែនរដ្ឋាភិបាលធំបំផុតក្នុងប្រទេសកម្ពុជា។ CCC បច្ចុប្បន្ន មានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ចំនួនជាង ១៦០។ CCC ត្រូវបានទទួលស្គាល់ដោយសារសមត្ថភាពរបស់ខ្លួនក្នុងការធ្វើការងារក្នុងភាពជាដៃគូ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ កែលម្អបរិយាកាសអំណោយផល និងឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងផ្នែកអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។ ការលើកកម្ពស់ប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ច គាំទ្រដល់ចក្ខុវិស័យរបស់ CCC សម្រាប់***ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា***។

CCC គឺជាសមាជិករបស់ Cambodia CSR Platform និងជាសមាជិករបស់បណ្តាញ OECD Watch។

www.csrcambodia.org

http://www.oecdwatch.org/

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
ផ្ទះលេខ ៩-១១, ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា
+៨៥៥ (០) ២៣ ២១៦ ០០៩
www.ccc-cambodia.org

## *សេចក្តីថ្លែងអំណរគុណ*

ការផលិតខិត្តប័ណ្ណផ្សព្វផ្សាយនេះអាចធ្វើទៅបានដោយសារមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីអង្គការASEAN CSR Network។ ខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ គឺជាការទទួលខុសត្រូវរបស់CCC ដែលត្រូវបានបង្កើតឡើងដោយលោកស្រី Serena Lillywhite ដែលជាទីប្រឹក្សាផ្នែក RBC របស់CCC។ CCC សូមថ្លែងអំណរគុណដល់ Ame Trandem (បណ្តាញ OECD Watch / មជ្ឈមណ្ឌល SOMO), Romina de Jong (CSR Platform Cambodia) និង Bophal Keat (UNOHCHR Cambodia) ដែលបានផ្តល់យោបល់ត្រឡប់ដ៏មានតម្លៃ។

ASEAN CSR Network

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

ខែកុម្ភៈ ឆ្នាំ២០១៧


Vision: Sustainable development for Cambodia
Goal: A strong and capable civil society, cooperating and responsive to Cambodia's development challenges
Mission: As a membership based organization, CCC works in inclusive partnership for good governance, enabling environment and sustainability of civil society organizations in Cambodia
Improved multi-stakeholder partnership in policy development and effective development cooperationat all levels
Increased capacity of CSOs for innovative response to development challenges
Strengthened active participation of CCC members and innovative services of CCC secretariat
CCC's roles:
Coordinator
Governance Champion
Advocate
Values:
- Integrity
- Responsiveness
- Quality
- Cooperation
- Inclusiveness
2016
2015
2014




Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge
គ.ស.ក
យុទ្ធសាស្ត្ររបស់កម្មវិធីប្រតិបត្តិការ
ដោយការទទួលខុសត្រូវរបស់ធុរកិច្ច និង
ទំនួលខុសត្រូវខាង
សង្គម
របស់សាជីវកម្ម
២០១៦-២០២១
ភាពជាដៃគូសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជា
Accountability
GPP
Symbol of Trust
25/08/2015
24/08/2018